**NEWS RELEASE**

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

# កម្ពុជា៖ អ្នកជំនាញការសិទ្ធិមនុស្ស អ.ស.ប សាទរចំពោះការទម្លុះទម្លាយភាពជាប់គាំនយោបាយ អំពាវនាវឲ្យមានការធ្វើកំណែទម្រង់ដូចដែលបានសន្យា

ទីក្រុងហ្សឺណែវ (២២ កក្កដា ២០១៤) - បន្ទាប់ពីមានការប្រកាសនៅថ្ងៃនេះ អំពីការព្រមព្រៀងគ្នារវាងគណបក្សនយោបាយធំៗទាំងពីរនៅកម្ពុជា ហើយក្រោយមក មានការដោះលែងសមាជិកគណបក្សប្រឆាំងមួយចំនួន ដែលបានចាប់ខ្លួននៅសប្តាហ៍កន្លងទៅនេះ អ្នករាយការណ៍ពិសេស អ.ស.ប ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោក សុរិយា ប្រាសាទ ស៊ូប៊ែឌី បានចេញសេចក្តីថ្លែងការណ៍មួយ ដែលមានខ្លឹមសារដូចខាងក្រោម៖

‟ខ្ញុំស្វាគមន៍យ៉ាងកក់ក្តៅចំពោះកិច្ចព្រមព្រៀងនយោបាយ ដែលបានសម្រេចនៅថ្ងៃនេះ ដោយមេដឹកនាំនៃគណបក្សនយោបាយធំៗពីរ ដែលនៅទីបំផុតបានទម្លុះទម្លាយភាពជាប់គាំងនយោបាយ ដែលបានលេបត្របាក់ប្រទេសនេះ អស់រយៈពេលជិតមួយឆ្នាំ។ ទន្ទឹមនេះដែរ ខ្ញុំស្វាគមន៍ចំពោះការដោះលែងបេក្ខជនតំណាងរាស្ត្រជាប់ឆ្នោតចំនួន ៧ រូប និងសកម្មជនមួយរូបទៀត នៃគណបក្សសង្គ្រោះជាតិ (CNRP) ក្រោយពីមានកិច្ចព្រមព្រៀងកាលពីព្រឹកមិញនេះ។ នៅទីបំផុត ភាគីទាំងពីរបានរកឃើញចំណុចរួមមួយ ដើម្បីឧត្តមប្រយោជន៍របស់ប្រជាជនកម្ពុជា។ គណបក្សទាំងពីរនេះ សាកសមនឹងទទួលបានការអបអរសាទរនេះពីយើង ហើយប្រជាជនកម្ពុជាទាំងអស់ មានសេចក្តីរីករាយជាខ្លាំងចំពោះជ័យជំនះដ៏ថ្លៃថ្លានេះ។″

‟ទោះជាយ៉ាងណាក៏ដោយ កិច្ចព្រមព្រៀងលើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គឺគ្រាន់តែជាការកត់សំគាល់ពីការចាប់ផ្តើមការងារពិតប្រាកដនៃដំណើរការធ្វើកំណែទម្រង់ស្ថាប័នរដ្ឋប៉ុណ្ណោះ។″ លោក ស៊ូប៊ែឌី បានមានប្រសាសន៍ដូច្នេះ។ ដោយសំដែងនូវក្តីសង្ឃឹមថា គណបក្សទាំងពីរ នឹងអនុវត្តកំណែទម្រង់នេះប្រកបដោយអត្ថន័យសម្រាប់ប្រទេសជាតិ ដោយឈរលើគោលការណ៍មនសិកាខ្ពស់ ជាជាងការគ្រាន់តែបង្ហាញពីកាលានុវត្តន៍នយោបាយជាបណ្តោះអាសន្ននោះឡើយ នេះបើតាមការបញ្ជាក់បន្ថែមរបស់អ្នករាយការណ៍ពិសេស៖ ‟នេះគឺជាឱកាសមួយសម្រាប់អនុវត្តកំណែទម្រង់ដ៏ទូលំទូលាយមួយ ដែលចរិតលក្ខណៈយូរអង្វែង ស្របតាមបទដ្ឋានអន្តរជាតិ ដូចបានគូសបញ្ជាក់នៅក្នុងរបាយការណ៍របស់ខ្ញុំ ស្តីពីកំណែទម្រង់ការបោះឆ្នោត កំណែទម្រង់ប្រព័ន្ធតុលាការ និងកំណែទម្រង់សភា ធ្វើយ៉ាងដើម្បីកុំឲ្យស្ថានការណ៍ដែលបានកើតមានតាំងពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ក្នុងខែកក្កដា ឆ្នាំ២០១៣ កើតមានជាថ្មីម្តងទៀត។″

លោកបានជម្រុញឲ្យភាគីទាំងពីរ ធ្វើការជាមួយគ្នា ដើម្បីបង្កើត ឬពង្រឹងស្ថាប័នរដ្ឋទាំងឡាយ ដែលមានទំនួលខុសត្រូវពង្រឹងការអនុវត្តន៍សិទ្ធិមនុស្ស និងការឃ្លាំមើលដោយឯករាជ្យ។

នៅទីបញ្ចប់ លោក ស៊ូប៊ែឌី បានកត់សម្គាល់ដោយក្ដីកង្វល់ថា បេក្ខជនតំណាងរាស្ត្រជាប់ឆ្នោតរបស់គណបក្សសង្គ្រោះជាតិចំនួនប្រាំពីររូប និងអ្នកគាំទ្រគណបក្សនេះមួយរូបទៀត ដែលត្រូវបានដោះលែងឲ្យនៅក្រៅឃុំនៅថ្ងៃនេះ នៅតែត្រូវប្រឈមនឹងការចោទប្រកាន់ធ្ងន់ធ្ងរជាដដែល ដែលអាចត្រូវបានគេប្រើប្រាស់ធ្វើជាឧបករណ៍មួយ សម្រាប់ការយាយីរំខានខាងនយោបាយ នៅពេលណាមួយ។

"ទន្ទឹមនឹងខ្ញុំស្វាគមន៍ចំពោះការបញ្ចប់នៃការឃុំខ្លួនសមាជិកគណបក្សសង្គ្រោះជាតិ និងអ្នកគាំទ្រគណបក្សនេះក្ដី ខ្ញុំនៅតែមានកង្វល់អំពីការអសមត្ថភាពនៃប្រព័ន្ធតុលាការ ក្នុងការដើរតួនាទីជាអ្នកត្រួតពិនិត្យលើអំណាចនីតិប្រតិបត្តិ ដូចបានបង្ហាញឲ្យឃើញយ៉ាងច្បាស់ តាមរយៈព្រឹត្តិការណ៍កាលពីប៉ុន្មានថ្ងៃកន្លងមកនេះ។ ជាជាងការដើរតួនាទីជាអ្នកត្រួតពិនិត្យ អង្គតុលាការទំនងជាដើរតួជាឧបករណ៍មួយរបស់អង្គនីតិប្រតិបត្តិទៅវិញ" លោកបានប្រសាសន៍ដូច្នេះ។

អ្នកជំនាញការ អ.ស.ប បានជម្រុញឲ្យភាគីទាំងពីរ ប្រកាសបើកដោយគ្មានការពន្យាពេល នូវដំណើរការអនុវត្តកម្មវិធីកំណែទម្រង់ប្រព័ន្ធតុលាការដែលមានយឺតយ៉ាវ ដែលគណបក្សទាំងពីរបានសន្យាចំពោះម្ចាស់បោះឆ្នោតរបស់ខ្លួន នៅក្នុងអំឡុងពេលនៃការបោះឆ្នោតកាលពីឆ្នាំមុន ដោយបានកត់សំគាល់ថា "ឥឡូវនេះ វាមិនត្រឹមតែអាចធ្វើបាន និងមិនអាចចៀសបាននោះទេ" ដោយមានតំណាងរាស្ត្រមកពីគណបក្សសង្គ្រោះជាតិ ចូលអង្គុយនៅអាសនៈរបស់ពួកក្នុងរដ្ឋសភាហើយនោះ "ប៉ុន្តែវាថែមទាំងមានសារៈសំខាន់ដាច់ខាតបំផុតទៀតផង។"

**ចប់**

*លោកសាស្ត្រាចារ្យ សុរិយា ប្រាសាទ ស៊ូប៊ែឌី ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជាអ្នករាយការណ៍ពិសេសស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងខែមីនា ឆ្នាំ២០០៩។ ក្នុងនាមជាអ្នករាយការណ៍ពិសេស លោកជាបុគ្គលឯករាជ្យ មិនចំណុះរដ្ឋាភិបាល ឬអង្គការណាមួយឡើយ ហើយបំរើការក្នុងសមត្ថភាពបុគ្គលលោកផ្ទាល់។ បច្ចុប្បន្នលោកជាសាស្ត្រាចារ្យផ្នែកនីតិអន្តរជាតិនៃសាកលវិទ្យាល័យលីដស៍ ចក្រភពអង់គ្លេស និងជាមេធាវីអាជីពមួយរូបនៃគណៈមេធាវីមី ឌីលថឹមភីល នៅទីក្រុងឡុង។ លោកជាអនុប្រធានសង្គមអាស៊ីនៃនីតិអន្តរជាតិ និងជាអ្នកនិពន្ធសៀវភៅពាក់ព័ន្ធនឹងគម្រោងសំខាន់ៗ ទស្សនាវដ្ដីអាស៊ីនៃច្បាប់អន្តរជាតិ បោះពុម្ពផ្សាយដោយរោងពុម្ពនៃសាកលវិទ្យាល័យខេមប្រីដជ៍។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រនេះ*
*http://www.ohchr.org/EN/HRBodies/SP/CountriesMandates/KH/Pages/SRCambodia.aspx*

*អ្នករាយការណ៍ពិសេសបានបញ្ជូនអនុសាសន៍របស់លោក នៅក្នុងរបាយការណ៍សំខាន់ៗចំនួនប្រាំ ទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប ស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។ លោក ស៊ូប៊ែឌី នឹងបង្ហាញរបាយការណ៍ សេចក្ដីសន្និដ្ឋាន និងអនុសាសន៍ចុងក្រោយបំផុត ទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប នៅខែកញ្ញា ឆ្នាំ២០១៤ ។ សូមពិនិត្យមើលរបាយការណ៍លើមុនៗរបស់លោក៖ http://ap.ohchr.org/documents/dpage_e.aspx?m=107*

*សិទ្ធិមនុស្ស អ.ស.ប គេហទំព័រប្រទេស – កម្ពុជា៖*
*http://www.ohchr.org/EN/Countries/AsiaRegion/Pages/KHIndex.aspx*

*សម្រាប់ព័ត៌មានបន្ថែម និង**ការសាកសួរព័ត៌មាន** សូមទាក់ទងមក ៖ កញ្ញា អ័លហ្គា ណាកាចូ តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩២៨ ៩៣៤៨ / អ៊ីម៉ែល onakajo@ohchr.org ឬ សរសេរទៅកាន់ srcambodia@ohchr.org*

**សិទ្ធិមនុស្ស អ.ស.ប ស្វែងយល់ពីយើង តាមរយៈបណ្តាញព័ត៌មានសង្គម ៖**

**ហ្វេសប៊ុក៖** https://www.facebook.com/unitednationshumanrights
**ទ្វីតធឺ៖** http://twitter.com/UNrightswire
**ហ្គោហ្គីល៖**Google+ gplus.to/unitednationshumanrights

**យូធូប៖** http://www.youtube.com/UNOHCHR

**បរិយាយសាច់រឿង ៖** http://storify.com/UNrightswire

**ឆែកមើលលិបិក្រមសិទ្ធិមនុស្សជាសកល៖** http://uhri.ohchr.org/en